# ពត៌មានប្រចាំថ្ងៃ

**MOI DAILY NEWS**

www.interior.gov.kh

## ពត៌មាន ប្រចាំថ្ងៃ របស់ក្រសួងមហាផ្ទៃ

ពីថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០០៥

### ពត៌មានសន្តិសុខសង្គម

រាជធានីភ្នំពេញ

-នៅថ្ងៃទី៣០/៨/២០០៥ វេលាម៉ោង ១០:៤៥នាទី នៅចំណុចផ្លូវលំ ក្នុងភូមិព្រៃពពេល សង្កាត់សំរោងក្រោម មានជនល្មើស ០៣នាក់ ជិះម៉ូតូ០១គ្រឿង បានប្លន់ជនរងគ្រោះឈ្មោះ ឃឿន សុខឃី ភេទប្រុស អាយុ ១៧ឆ្នាំ យកបានម៉ូតូ០១គ្រឿង ។

ខេត្តកំពង់ស្ពឺ

-ថ្ងៃទី២៩/៨/២០០៥ វេលាម៉ោង ១៨:៣០នាទី នៅចំណុចខាងជើងវត្តស្លាបលែង ឃុំស្វាយ រំពារ ស្រុកបសេដ្ឋ មានជនល្មើស ០២នាក់ បានស្ទាក់ប្លន់-វាយទៅលើជនរងគ្រោះឈ្មោះ នៅ សុភ័ក្រ ភេទប្រុស អាយុ២២ឆ្នាំ បណ្តាលអោយរបួសធ្ងន់ រួចពួកវាយកបានម៉ូតូ០១គ្រឿង ជិះគេចខ្លួនបាត់ ។

ក្រុងកែប

-នាថ្ងៃទី២៨/៨/២០០៥ ប្រជាពលរដ្ឋបានប្រទះឃើញសាកសពទារក ភេទប្រុស អាយុប្រហែល ០៤ខែ នៅក្នុងព្រៃ តាមបណ្តោយផ្លូវចូលភ្នំវល្លិ ភូមិដំណាក់ចង្អើរ សង្កាត់ព្រៃធំ ខណ្ឌកែប សំភារៈនៅនឹងកន្លែងសាកសពរួមមាន បាវជី១, កំប៉ុង ទឹកដោះគោ១, ក្រម៉ា១ ។ តាមការសន្និដ្ឋានរបស់ ការិយាល័យជំនាញទារកនេះត្រូវបានជនមិនស្គាល់មុខយកមកទុកចោល បណ្តាល អោយស្លាប់តែម្តង ។

ខេត្តកំពង់ធំ

- កាលពីថ្ងៃទី២៧/៨/២០០៥ វេលាម៉ោង ១៩:៣០នាទី នៅ ភូមិស្វាយរៀង ឃុំរុងរឿង ស្រុកស្ទោង មានករណី ប៉ុនប៉ងធ្វើឃាត០១ករណី បង្កដោយជនល្មើសមិន ស្គាល់មុខ បានបាញ់ដោយចំពាមផ្លែព្រួញទៅលើជនរងគ្រោះឈ្មោះ ឌិប ឌុន ភេទប្រុស អាយុ ៥០ឆ្នាំ បណ្តាលអោយរបួសធ្ងន់ ក្នុងខណៈពេលដែលជនរងគ្រោះចុះពីលើផ្ទះមកដុតភ្លើងគោក្រោមផ្ទះ សមត្ថកិច្ចកំពុង ធ្វើការស្រាវជ្រាវបន្ត ។

រាល់ករណីខាងលើ កំលាំងសមត្ថកិច្ចកំពុងស្រាវជ្រាវ ស្វែងរក ចាប់ខ្លួនជនល្មើសបញ្ជូនទៅតុលាការ ។


អាស័យដ្ឋានៈ បន្ទប់លេខ១១៤ អគារទីស្តីការរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ
ទូរស័ព្ទ/ទូរសារៈ៨៥៥-២៣-៧២៦០៥២ Email:info@interior.gov.kh

## គ្រោះថ្នាក់ផ្សេងៗ

<u>រាជធានីភ្នំពេញ :</u> ថ្ងៃទី២៩/៨/២០០៥ វេលាម៉ោង ១៥:៣០នាទី នៅក្នុងភូមិសាស្ត្រ ខណ្ឌឫស្សីកែវ ខណ្ឌ ដង្កោ មានភ្លៀងខ្យល់ព្យុះបណ្តាល អោយខូចខាតផ្ទះសម្បែងប្រជាពលរដ្ឋចំនួន ១៥ខ្នង (ខណ្ឌឫស្សីកែវ ១៤ខ្នង, ខណ្ឌដង្កោ ០១ខ្នង) តែពុំបណ្តាលអោយមានគ្រោះថ្នាក់ ដល់អាយុជីវិតឡើយ ។

## លទ្ធផលកិច្ចប្រតិបត្តិការ

<u>ខេត្តកំពង់ស្ពឺ :</u> -កំលាំងចំរុះ រួមមានគណៈបញ្ជាការឯកភាពស្រុកឱរ៉ាល់ ដែលមានកងកំលាំងនគរបាល កងរាជអាវុធហត្ថ កំលាំង បរិស្ថាន រួមនឹងប្រជាពលរដ្ឋចំនួន ០៥ភូមិបានចុះធ្វើការរុះរើការហ៊ុំព័ទ្ធរបងយកដីធ្វើជាកម្មសិទ្ធនៅតំបន់ជុំវិញតេទឹកពុះរហូតដល់ភូមិបន្ទាយស្វា។ ជាលទ្ធផលយើងរើបអូស ដកហូតដុតបំផ្លាញចោលនូវបង្គោររបង ចំនួន១៧.៣៧០ដើម ។

<u>រាជធានីភ្នំពេញ :</u> កំលាំងសមត្ថកិច្ចបានបង្ក្រាបករណី រំលោភ ០១ករណី ឃាត់ខ្លួន០១នាក់, ករណីជួញដូរមនុស្សទៅប្រទេសថៃ ០១ករណី ឃាត់ខ្លួន០៥នាក់ សង្គ្រោះនារីរងគ្រោះ០៧នាក់, ករណីប្លន់គំរាមយកលុយ ០១ករណី ឃាត់ខ្លួន០១នាក់ ករណីប្លន់ ០១ករណី ឃាត់ខ្លួន០១នាក់, ករណីឆបោក ០១ករណី ឃាត់ខ្លួន០១នាក់ , ករណីលួច ០៥ករណី ឃាត់ខ្លួន០៩នាក់, ករណីឆក់០៥ករណី ឃាត់ខ្លួន០៩នាក់ , ទទួលផលចោរកម្ម ០១ករណី ឃាត់ខ្លួន ០២នាក់ និងរំលោភសេចក្តីទុកចិត្ត០១ករណី ឃាត់ខ្លួន០១នាក់ ។

<u>ខេត្តកំពង់ចាម :</u> កំលាំងសមត្ថកិច្ចបានបង្ក្រាបករណី ជួញដូរគ្រឿងញៀន ០១ករណី ឃាត់ខ្លួន០១នាក់ និងករណីលួចប្រជារាស្ត្រ ០២ករណី ឃាត់ខ្លួន០៤នាក់ ។

<u>ក្រុងកែប :</u> កំលាំងសមត្ថកិច្ចបានបង្ក្រាបករណី លួចប្រជារាស្ត្រ ០១ករណី ឃាត់ខ្លួន០១នាក់ ។

<u>ក្រុងប៉ៃលិន :</u>កំលាំងសមត្ថកិច្ចបានបង្ក្រាបករណី បង្ករបួសស្នាម ០១ករណី ឃាត់ខ្លួន០១នាក់ ។

<u>ខេត្តបាត់ដំបង:</u> កំលាំងសមត្ថកិច្ចបានបង្ក្រាបករណី ចាប់មនុស្សជំរិតយកប្រាក់ ០១ករណី ឃាត់ខ្លួន០៤នាក់ ។

<u>ខេត្តបន្ទាយមានជ័យ :</u> កំលាំងសមត្ថកិច្ចបានបង្ក្រាបករណី រំលោភ ០១ករណី ឃាត់ខ្លួន០១នាក់ ។

<u>ខេត្តសៀមរាប:</u> កំលាំងសមត្ថកិច្ចបានបង្ក្រាបករណី ជួញដូរគ្រឿងញៀន ០១ករណី ឃាត់ខ្លួន០១នាក់ ដកហូតថ្នាំយ៉ាម៉ាចំនួន១០០គ្រាប់ ។

<u>ខេត្តកំពង់ឆ្នាំង :</u> -កំលាំងសមត្ថកិច្ចបានបង្ក្រាបករណី ជួញដូរគ្រឿងញៀន ០១ករណី ឃាត់ខ្លួន០១នាក់ និងករណីលួច ០១ករណី ឃាត់ខ្លួន០២នាក់ ។

<u>ខេត្តកណ្តាល:</u>កំលាំងសមត្ថកិច្ចបានបង្ក្រាបករណី លួចប្រជារាស្ត្រ ០១ករណី ឃាត់ខ្លួន០២នាក់ ។

( ប្រភពព័ត៌មានពីអគ្គស្នងការដ្ឋាននគរបាលជាតិ )



អាស័យដ្ឋានៈ បន្ទប់លេខ១១៤ អគារទីស្តីការរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ
ទូរស័ព្ទ/ទូរសារៈ៨៥៥-២៣-៧២៦០៥២ Email:info@interior.gov.kh